# ការសំភាសន៍ជាលើកទីពីររបស់ អ្នកមីង ទូច ស្រី

កៈ អ្នកដែលសំភាសន៍ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះទូច ស្រី

## <u>ការសង្ខេបលើកទីពីររបស់ អ្នកមីង ទូច ស្រី</u>

អ្នកមីងទូច ស្រី គាត់មានជីវិតមួយដែលតស៊ូខ្លាំងបំផុត
គាត់ហើយនឹងម្ដាយបានខំរកស៊ីបេះត្រកួន កាត់កំប្លោកដើម្បីហាលធ្វើខ្សែយកទៅលក់
ហើយត្រូវងើបពីព្រឹកដើម្បីយកទៅអោយម៉ូយបើងើបមិនទាន់គេនឹងយកម៉ូយអស់។
អ្នកមីងបានឆ្លងកាត់របបសង្គ្រាមដល់សែនពិបាក ហើយ
បើសិនជាអ្នកណាគេធ្វើខុសគេនឹងយកទៅសម្លាប់ចោល គេមិនសម្លាប់មនុស្សពេលថ្ងៃទេ
គឺអោយតែពេលយប់គឺគេបានហើយមនុស្សដែលគេគិតថាធ្វើខុសហ្នឹងទៅសម្លាប់ពេលយប់
ហើយគាត់មិនបានរស់នៅជិតម្ដាយទេ គាត់ត្រូវរស់នៅបែកពីម្ដាយ ព្រោះជាច្បាប់របស់អង្គការ
បើហ៊ានបំពាននឹងសម្លាប់។
បែកពីរបបសង្គ្រាមគាត់ក៏ខំប្រឹងរកស៊ីហើយក៏បានជួបស្វាមីហើយរៀបការ ជាមួយគ្នា
ឥឡូវគាត់មានកូន១០នាក់តែបានស្លាប់មួយនាក់ទៅហើយ
គាត់មានស្ថានភាពនឹងជីវភាពមិនស្រួលទេគឺមើលទៅវេទនាខ្លាំងណាស់ ព្រោះគាត់ឈឺ ប្ដីឈឺ
កូនឈឺផងដែរ។

កៈ
អូខេជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមបានសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងម្ដងទៀត នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា
ជាអ្នកសំភាសន៍អំពីជីវិតអ្នកមីងនៅក្នុងថ្ងៃនេះ ថ្ងៃដែលយើងសំភាសន៍គឺនៅក្នុងខែមិនា
ឆ្នាំ២០១៨ ការសំភាសន៍នេះមានទីតាំងស្ថិតនៅក្នុងភូមិព្រែកហូរខាងលិច ឃុំ ព្រែកហូរ
ក្រុងតាខ្មៅ ខេត្តកណ្ដាល
ប្រទេសកម្ពុជា។អ៊ីចឹងដោយសារពេលមុនពួកយើងអត់បានសំភាសន៍នៅគ្រប់កន្លែងនៃជីវិតរបស់អ្នកមីង
អញ្ចឹងថ្ងៃនេះពួកយើងនឹងចង់សំភាសន៍ជីវិតរបស់អ្នកមីងបន្ថែមទៀតដើម្បីដឹងអោយបន្ថែម

ទៀតអំពីជីវប្រវត្តិរបស់អ្នកមីងដើម្បីទុកអោយកូនចៅអ្នកមីងជំនាន់ក្រោយបានស្គាប់ !!
អ៊ីចឹងអ្នកមីងសូមប្រាប់ឈ្មោះពេញអ្នកមីងម្តងទៀត!!
ខ៖ ទូច ស្រី។

ក៖ អញ្ចឹងអ្នកមីងនិយាយពីជីវិតរបស់អ្នកមីងបន្ថែម
ដោយសារពេលមុនអត់ទាន់បាននិយាយអស់អ៊ីចឹងអ្នកមីងសំរាប់ការសិក្សារបស់អ្នកមីងរៀន
បានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ រៀនបានថ្នាក់ទីមួយដល់ពេលម៉ែញុំម
ម៉ែញុំមគាត់នេះពេកទៅគាត់អត់ពេកញុំមក៏ឈប់រៀនទៅ។

ក៖ចាំ!!

ខ៖ ញុំមឈប់រៀនទៅញុំមក៏ដើរលក់ដូរ!!

(ស្វាមី)៖ គាត់ចាស់ពីដើមជំងឺស្ទះ។

ខ៖ ម៉ែញុំមពីដើមកើតជំងឺផងអីផង ណាមើលម៉ែផងអីផងអ៊ីចឹងហាំ!!

ក៖ ក៏ឈប់រៀនឈប់អីទៅ?

ខ៖ ក៏ឈប់រៀនទៅ
ឈប់រៀនទៅហើយណាមួយកូនក៏ឈឺទៅលក់ផ្ទះលក់អីមើលម៉ែអញ្ចឹងទៅណាស់!!អ៊ីចឹងបាន
ញុំមឈប់រៀនទៅ ញុំមរៀនបានតែត្រឹមថ្នាក់ទីមួយហ្នឹង!!

ក៖ ហើយរៀនហ្នឹងពេលមុនបែកសង្គ្រមហ្នឹងហើយហីក៏មុនចូលសង្គ្រាមបានចូលរៀន?

ខ៖ បែកសង្គ្រាមហើយបានចូលរៀន!!

ក៖ចាំ!!

ខ៖សាលាចាក់អង្រែយើងនេះ។

ក៖ហ្ហំចាក់អង្រែភូមិ៣ហ្នឹងហី?

ខ៖ ភូមិ២។

ក៖ភូមិពីរហោ??

ខ៖ ទល់មុខវត្ត វត្តចាក់អង្រែក្រោមហ្នឹងហើយ។

ក៖ហ្នឹងហើយ អីចឹងសាលាហ្នឹងគេហៅសាលាចាក់អង្រែក្រោមភូមិពីរអីចឹងទៅមីងណេះ?

ខ៖ ហ្នឹងហើយ។

ក៖ មីងរៀនចូលបានប៉ុន្មានខែបានឈប់រៀនហ្នឹង?មួយឆ្នាំពេញឬក៏ម៉េច?

ខ៖ អត់បានដល់មួយឆ្នាំផងហ្នឹង។

ក៖ហ្ហូ!!

ខ៖ ដល់បានដល់មួយឆ្នាំផងម៉ែស្ទះ ងាកម៉ែស្ទះរត់មកផ្ទះមកមើលគាត់អីចឹងទៅណាស់!!

ក៖ចាំ!!

ខ៖គាត់ស្ទះផង គាត់អួល ចុកផង គាត់ក្អួតផងអីផងអីផងហ្នឹង។

ក៖ចាំ!

ខ៖អត់បានមើលគាត់អាលែងទៅកាត់កំប្លោកលក់ទៅយកលុយមកទិញថ្នាំអោយគាត់លេប
ទៅ ហ្នឹងមានតែប៉ុណ្ណឹងទេ!!

ក៖ ចាំ!!អញ្ចឹងបងមីងគាត់មានជួយមើលម៉ែទេអីចឹង?

ខ៖ ចុះបងៗគេនៅឆ្ងាយៗហ្នឹង គេនៅដល់ពេលចិន
យើងនៅព្រៃកហូរណោះហ្នឹងមានពេលឯណាមកមើលម៉ែ។

(ស្វាមី)៖ បងហ្នឹង បងធ្វើទាហានទេសម័យហ្នឹងហាំ!!

ខ៖ ហ្នឹងហើយ។

ក៖ អញ្ចឹងបងប្រុសសម័យហ្នឹងធ្វើទាហានដែរ?

ខ៖ ចាំ!!

ក៖គេចាប់ទាហានអាចំបក់ចាប់ទាហានមីងហី?

(ស្វាមី)៖ ចូលធ្វើហើយក៏រត់ ដល់រត់តាមចាប់យកទៅវិញ។

ក៖ ហ្នំអីចឹងចំបក់អាគេបែកហើយចាប់ទាហានហ្នឹងហោ?

ខ៖ ហ្នឹងហើយ។

(ស្វាមី)៖ ហ្នឹងហើយ អាណាមិនល្បីខេត្តកណ្តាល។

ក៖ ចាប់ទាហានគ្រប់កន្លែងពូ។

ខ៖ចាំ!!

ក៖ អ៊ិចឹងអ្នកមីងសំរាប់ពេលនៅរៀនហ្នឹងមានមិត្តភក្តិអីអត់ពេលហ្នឹង?

ខ៖ អត់មានផង។

ក៖ ម៉េចអីចឹង?ដើរទៅណាតែឯងតែឯងអីចឹងទៅ?

ខ៖ហ្នឹងហើយ ដើរតែឯងតែឯងទៅ។

(ស្វាមី)៖ រៀនលឿនពេកមានម៉េចទាន់!!

ខ៖ រួចទៅមានពេលណានេះមាន រត់ទៅកាច់កំប្លោកទៅម៉ោង៣យប់បានទាត់គេ រត់អត់ទាន់គេគេកាត់ម៉ូយអស់ឥឡូវហើយ។

ក៖ ហ៊ីអីចឹងទៀត?

ខ៖ ហ្នឹងហើយ។

ក៖ មីងទៅកាត់កំប្លោកនៅណាវិញ?

ខ៖ តាមបឹង។

កះ អាបឹងក្រោយៗហ្នឹងហី?

ខះ ហ្នឹងហើយ !!អាតាមបឹងក្រោយៗហ្នឹង
ដើរតាមនេះទៅដូចឈរអឺចឹងទៅបានសារអាមុនទៅណាស់បានសារហើយដាក់ហាលបន្តៗអឺ
ចឹងទៅ!!

កះចាំ!!

ខះណាហ្នឹងហើយហើយយប់ឡើងមកពីបឹងវិញទៅយើងទៅប្រើអាខ្សែកំប្លោកហ្នឹងហាំ
យកអាខ្សែកំប្លោកហ្នឹងយកទៅច្រលក់ទឹកអោយវារីក
អាវារីកឡើងធំទៅចងទៅងើបម៉ោង៣យកទៅលក់បានទាន់គេ អឺចឹងគេកាក់អស់ហើយ។

កះចាំ!!!

ខះ ហ្នឹងហើយ ដល់ពេលដាក់តាមម៉ូយ ដូចថាបងឯងលក់ស្ពៃអឺចឹងដាក់មួយជុំអញ្ចឹងទៅ
ដាក់កន្លែងផ្សេងទៀតទៅ លៃម៉េចអោយបានមុនគេ បើមិនបានមុនគេទេគេដាក់អស់ហើយ។

កះនៅផ្សារណាវិញមីង?

ខះ ផ្សារច្បារអំពៅយើងហ្នឹង។

កះតែពេលហ្នឹងផ្សារច្បារអំពៅមានយូរណាស់ហើយអញ្ចឹងហើយមីងណោះ?

ខះ មានយូរហើយ។

(ស្វាមី)ះ មានតាំងពីសង្គមហ្នំ!!

កះ ហ្ន៎ មានតាំងពីមុនសង្គ្រាមទៀត!!!

ខះ ហ្នឹងហើយ។

កះ ហើយអឺចឹងដល់ពេលបានលុយពីហ្នឹងមក យកទៅ!!

ខះ ផ្គត់ផ្គង់ម៉ែ!!

កះ ជួយម៉ែជួយអីទៅ ទិញថ្នាំពេទ្យទិញអីទៅ?

ខ៖ចាំ!!!

ក៖ មីងនៅពីក្មេងពេលរៀនអីវ៉ាន់ដែរធ្លាប់ធំឡើងស្រម៉ៃចង់ថាធ្វើអីគេអត់?

ខ៖ អត់មានចង់ធ្វើអីផង។

ក៖អត់ដែលធ្លាប់គិតសោះម៉ងហើយហោ?

ខ៖អត់!!

ក៖អត់មានដែលថាធំឡើងចង់ធ្វើគ្រូពេទ្យ ឬក៏ធ្វើអ្នកលក់ដូរអីៗអញ្ចឹងហ្ន៎??

ខ៖ ម៉ែឪក្រអត់មានអារម្មណ៍លួចគិត អត់មានអារម្មណ៍។

ក៖ តែមានអ្នកខ្លះហាំ
ទោះមានទោះក្រអីក៏ដោយអ្នកខ្លះនៅតែគិតអ៊ីចឹងថាធំឡើងចង់ធ្វើអីថាធ្វើអីអោយសំរេចគោលបំណងហ្នឹងអ៊ីចឹងណាស់មីង!!!

ខ៖ អត់មានគិតអីរវល់ខ្វល់តែម៉ែឈឺ រត់ទៅកាច់កំប្លោកផង ហើយងាកទៅម៉ែស្លះផង គេមកតាមអញ្ចឹងទៅ បោះចោលកំប្លោកមួយសារអ៊ីចឹងទៅរត់ទៅមើលគាត់អញ្ចឹងទៅ រត់ទៅមើលគាត់អញ្ចឹង រត់មកមើលគាត់ទាំងអញ្ចឹងទៅណាស់។

ក៖ចាំ!!

ខ៖ ហ្នឹងហើយ។

ក៖ មីងអាខ្សែកំប្លោកហ្នឹងធ្វើម៉េចខ្លះទៅ វាស្ងួតឬក៏ម៉េចដើម្បីយកអោយគេហ្នឹង។

ខ៖ ស្ងួតច្រើសម៉ងហាំ!!ស្ងួតម៉ងហាំ!!

(ស្វាមី)៖ ដល់យើងច្រលក់ទឹកទៅវាទៅជាខ្សែ។

ខ៖ ច្រលក់ទឹកទៅវាទៅជារីក រីកធំៗហាំ!!

ក៖ មាំណាស់មីងហីខ្សែកំប្លោក?

ខ៖ ហ្នឹងហើយ យកធ្វើអង្រឹងអង្គអីបានតើ!!

ក៖ចាំ!!

ខ៖ ហ្នឹងហើយ ។

ក៖ អញ្ចឹងពេលអាកំប្លោកហ្នឹង ទៅកាត់វា កាត់ហើយឈូតមែនមីង?

ខ៖ ចាំ!!កាត់ស្លឹកវាអោយស្អាត កាត់ស្លឹកវាអញ្ចឹង ស្លឹកវាស្ងួតៗអញ្ចឹង
អោយបានវែងអញ្ចឹងទៅណាស់យើងឈូតវាទៅ កាត់អាឬសវាចេញទៅអាឬសវាទៅ
ហើយបន្ទាប់មកយើងយកទៅហាល ដាក់ហាល។

ក៖ចាំ!!

ខ៖ ដាក់ហាលហើយដល់ពេលហាល៣ ៤ថ្ងៃអញ្ចឹងទៅបានសារចេញបានសារម្តង
ចេះតែហាលបន្តបន្ទាប់អញ្ចឹងបន្តបន្ទាប់អញ្ចឹងសារម្តងដល់តែស្ងួតហើយបានសារម្តងហើយ
ចេះតែហាលបន្តបន្ទាប់ទៅ កាត់រាល់ថ្ងៃហាលរាល់ថ្ងៃអញ្ចឹងទៅណាស់។

ក៖ហ៊ីៗ!!

ខ៖ ហ្នឹងហើយ។

ក៖ អញ្ចឹងមីងការលក់ដូរអាហ្នឹងបានលុយច្រើនអីគ្រាន់បើអីអត់?

ខ៖ កាលហ្នឹងចាយល្មម កាលហ្នឹងអត់ទាន់មានរ៉ឺម៉កអត់ទាន់មានអីទេណាស់!!ហ្នឹងហើយ។

ក៖ចាំ!!!

ខ៖ជំនាន់ហ្នឹងអត់ទាន់ប្រើស្បោងទេ ដល់ពេលឥឡូវគេប្រើស្បោង
បើសិនជាអត់ប្រើស្បោងស្មាតែសល់ហី ខ្ទេចអស់ឥឡូវហ្នឹង មែនតើខ្ទេចអស់ឥឡូវហ្នឹង។

ក៖ ខ្ទេចកំប្លោកនៅមុខផ្ទះហ្នឹងមីងហោ?

ខ៖ ហ្នឹងហើយ។

ក៖តែញ៉ុមគិតថាកន្លែងខ្លះគេនៅតែប្រើកំប្លោកចងដែរតើមីងហោ?

(ស្វាមី)៖ ឥឡូវហ្នឹងវាមានដែរតែមានតិចតួច!!

ខ៖ មានតិចតួច។

(ស្វាមី)៖ ហើយអញ្ចឹងទោះបីយើងយកទៅលក់ក៏វាមិនឃើញលុយដែរ។

ក៖ ចាំពិបាកណាស់អ៊ីចឹង។អ៊ីចឹងមីងសំរាប់ការរៀបការរបស់មីងហាំ
មីងរៀបការជាមួយពូតាំងពីឆ្នាំណាមកវិញ?

(ស្វាមី)៖ តាំងពីឆ្នាំ៨៣(១៩៨៣)

ខ៖ តាំងនៅទូចៗហ្នុំ!!

ក៖ អាយុប៉ុន្មានវិញមីងរៀបការ?

(ស្វាមី)៖ អាយុ១៨។

ខ៖ ១៨។

ក៖ មីងអាយុ១៨ឆ្នាំ?

ខ៖ ចាំ!!

ក៖ ហើយការពូនិយាយមិញការឆ្នាំ១៩៨៣ណោះ?

ខ៖ចាំ!!

ក៖
អញ្ចឹងមីងការរៀបការហ្នឹងត្រូវបានរៀបចំឡើងដោយឪពុកម្តាយឬក៏អ្នកមីងស្រលាញ់ពូអីវ៉ាន់
ដោយចិត្តឯង?

(ស្វាមី)៖ កាលពីដំបូងស្រលាញ់គ្នា។

ខ៖ ស្រលាញ់គ្នាហ្នឹង។

(ស្វាមី)៖ ដល់ស្រលាញ់គ្នាទៅចាស់ៗគេចាប់ផឹមជាគូអ៊ីចឹងទៅ។

ខ៖ ពេលហ្នឹងញ៉ុមលក់ខ្សែកំប្លោកហ្នឹងមកស្រលាញ់ញ៉ុមពេលញ៉ុមលក់ខ្សែកំប្លោកហ្នឹង ហើយគេណោះគេលីសែងញ៉ុមលក់ខ្សែកំប្លោក។

ក៖ហ្ន៎!!

ខ៖ ហ្នឹងហើយ។

ក៖ អ៊ីចឹងក៏ជួបគ្នាស្រលាញ់ទៅ?

ខ៖ ហ្នឹងហើយ។

ក៖ ហើយបានអោយម៉ែឪមកស្ដីដណ្ដឹងអោយហ្នឹង?

ខ៖ចា៎!!

ក៖ ជួបគ្នាដំបូងនៅផ្សាឬក៏នៅណា?

ខ៖ នៅផ្សារ។

ក៖ បានប៉ុន្មានខែបានរៀបការមីង?

ខ៖ ចា៎?

ក៖ បានប៉ុន្មានខែបានរៀបការ?

(ស្វាមី)៖ ហ៊ីកន្លះខែ។

ខ៖ កន្លះខែ។

ក៖ ហ៊ីលឿនម្លេះ។

ខ៖ តែមិនបានការទេ រៀបតិចតួចព្រោះសុទ្ធតែអ្នកអត់ហ្ន៎!!

ក៖ហ្ន៎!!

ខ៖ បានសែនតិចតួចហ្នឹង។

កៈ
ដោយសារពេលហ្នឹងវាក៏មិនសូវមានអីណាស់ណាដែរមនុស្សគ្រប់គ្នាសុទ្ធតែពិបាកៗទាំងអស់ហ្នឹង!!

ខៈ ពិបាកខាងនេះក៏អត់ខាងណោះក៏អត់ដែរហ្នឹងហា!!

កៈចាំ!!

ខៈ
ខាងឪពុកក្មេកញ៉ុមក៏អត់ខាងញ៉ុមនេះក៏អត់គ្រាន់តែសែនបង្គ្រាប់កិច្ចអោយចាស់ទុំដឹងឮអីចឹងទៅណាស់!!

កៈចាំ!!

ខៈហ្នឹងហើយ។

កៈ ហើយអីចឹងពេលហ្នឹងមានថ្លៃជំនូនទេអីចឹង?

ខៈដឹងមានមិនមានទេ។

កៈ ពេលហ្នឹងអោយទេអោយថ្លៃជំនូនទៅខាងស្រីអត់?

(ស្វាមី)៖ អោយតើ!!!

កៈ អោយជាអីគេវិញ?

(ស្វាមី)៖ អោយជាផ្លែឈើនំចំណី អាស្អីគេអាថ្លៃទឹកដោះគេអាម៉េចនោះ!!

កៈ ហ្នំអីចឹងបានអោយដែរមីងណេះ?

ខៈ ចាំ!!

កៈចាំអោយទៅខាងម៉ែទៅ!!

(ស្វាមី)៖ អោយទៅម៉ែ ដល់ពេលការហើយគាត់អោយមកវិញ។

កៈ
អ៊ីចឹងអ្នកមីងពេលអ្នកមីងរៀបការជាមួយលោកពូហើយអ្នកមីងមានកូនប្រុសស្រីប៉ុន្មាននាក់ដែរ?

(ស្វាមី)៖ រហូតមកដល់ពេលនេះមានកូន៩នាក់។

ខ៖ ៩នាក់។

កៈ អ្នកមីងមានកូន៩នាក់?

ខ៖ ចាំ!!

កៈហើយស្រីប៉ុន្មានប្រុសប៉ុន្មាន?

(ស្វាមី)៖ ស្រី៤ប្រុស៥។

ខ៖ បែកបែកគ្នាអស់ហើយ។

កៈ តែពួកគាត់សុទ្ធតែនៅៗទាំងអស់តើមីងហេ?

(ស្វាមី)៖ នៅទាំងអស់។

ខ៖ នៅទាំងអស់ហ្នឹង។

(ស្វាមី)៖ ចិញ្ចឹមកូនមិនអោយស្លាប់មួយណាទេ!!

ខ៖ នោះនោះអីវ៉ាន់ហ្នំ !!មីហើមមិញហើយអាមិញហ្នឹងមួយ នោះមីវាលើគ្រែនោះ។

កៈ ចាំ ហ្នឹងកូនមីងដែរ?

ខ៖ ចាំ!!

កៈ ហ្នឹង សុទ្ធតែមាឌដល់ករហើយប៉ុនខ្សុចដែរ
បងប្អូនជីដូនមួយគេ។អ៊ីចឹងនៅហ្នឹងជុំគ្នាទាំងអស់ឬក៏នៅណា?

ខ៖ ផ្ទះចង្អៀតពេក។

(ស្វាមី)៖ អត់ទេមានផ្ទះមួយកំនាត់។

ខ៖ ចង្អៀតពេក។

(ស្វាមី)៖ ដូចដីទំនប់មួយកំណាត់អ៊ីចឹងយើងមានមួយកំណាត់ហាំ!!ក៖ចាំ!!(ស្វាមី)៖ ប៉ុន្តែនៅក្រោយគេ។

ក៖តែដីហ្នឹងទិញទេមីងណេះ?

ខ៖ទិញ។

ក៖ ទិញហើយអ៊ិចឹង !! ចុះព្រមធ្វើផ្ទះខ្ពស់នៅទាំងអស់គ្នា ចាំនៅផ្ទះជួលធ្វើអីអ្នកមីង?

ខ៖អត់លុយ។

(ស្វាមី)៖ អត់លុយ វាអញ្ចេកអ្នកគ្រូ វាយ៉ាប់ផ្លូវផ្លូវតូច។

ខ៖ យ៉ាប់ផ្លូវហើយផ្ទះហ្នឹងវាពុកផង នៅគ្នាច្រើនខ្លាចវាបាក់ ។

ក៖ហ៊ឺ!!

ខ៖ដើរសុទ្ធតែលបៗហ្នឹងផ្ទះហ្នឹងហ្នំ!!

ក៖ មីងប្រាប់ឈ្មោះកូនទាំងអស់មើល ឥឡូវមីងអ្នកនិយាយមើល ឥឡូវឈ្មោះកូនឈ្មោះអីគេខ្លះពីបងគេរហូតដល់ពៅគេ។

ខ៖ បងគេបង្អស់ឈ្មោះមីខូច។

(ស្វាមី)៖ ព្រំ វណ្ណី។

ក៖ ទី២?

ខ៖ ទី២!!

(ស្វាមី)៖ មីទ្រា ស្លាប់ហើយមិនបាច់និយាយទេ មាន១០ប៉ុន្តែស្លាប់មួយ។

ក៖ ហ្នំអាយុប៉ុន្មានបានកូនមួយហ្នឹងស្លាប់អ្នកមីង?

(ស្វាមី)៖ ២ខួប។

ខ៖ អាយុញ៉ុមហោ?

ក៖ អត់ទេអាយុកូន ថាស្លាប់ហ្នំ!!ពូថាមិញ២ខួបណោះ?

ខ៖ចាំ!!!

ក៖ ចាំ អញ្ចឹងមួយឈ្មោះអីគេមិញដំបូងមិញ?

(ស្វាមី)៖ ព្រំ វណ្ណី។

ក៖ ព្រំ វណ្ណី!! បន្ទាប់មក?

(ស្វាមី)៖ ហើយបន្ទាប់មកព្រំ វណ្ណនេត។

ក៖ ឥឡូវមីងនិយាយមើល ឥឡូវកូនមិនចាំបាច់តាមលេខរៀងក៏បានដែរ!!

ខ៖ ញ៉ុមអត់សូវចាំទេ។

ក៖ អ្នកណាគេអត់ស្គាល់ឈ្មោះកូនម៉េចទេនេះ!!!!ឥឡូវចាំតិចទៀត ឥឡូវមីងនិយាយសិន បើខ្វះប៉ុន្មានចាំពូជួយបន្ថែម។ ឥឡូវឈ្មោះវណ្ណីហើយហើយ មីងចាំមួយទៀត?

ខ៖ វណ្ណនេត។

ក៖ វណ្ណនេត?

ខ៖ វណ្ណនេតហើយដារ៉ាហី?

(ស្វាមី)៖ អត់ទេ!!

ខ៖ អ្នកណាគេទេ។

(ស្វាមី)៖ នោះមីនាងចុះមក ព្រំ វណ្ណា។

ខ៖ ព្រំ វណ្ណា។

ក៖ វណ្ណា ហើយអ្នកណាគេទៀត?

(ស្វាមី)៖ ចុះមក!!

ខ៖ អាទ្រា!!

(ស្វាមី)៖ អត់ទេ អាដារ៉ា អាមួយនេះប៉ុនពាងទីនេះមិញ(ឈរនៅជិតគាត់មុនហ្នឹង)

ក៖ ហ្នឹងកូនមីងដែរ?

ខ៖ ចាំ!!

ក៖ ដារ៉ា ហើយអ្នកណាគេទៀត?

(ស្វាមី)៖ ដារី។

ក៖ ដារី។

ខ៖ ហើយឈ្មោះអីទៀត !!អាពុទ្រា!!

(ស្វាមី)៖ ហ៊ីនៅតែអាពុទ្រា អាពុទ្រាកូនទី២ហាំ!!

ខ៖ ហ្នឹងហើយអត់ដឹងប៉ុន្មានទេញ៉ុមអត់សូវចាំ។

(ស្វាមី)៖ ដារីហើយ!!

(កូន)៖ ស្រីទូច អាពៅ ស្រីពុធ។

(ស្វាមី)៖ ដារីហើយវណ្ណឌី។

ក៖ វណ្ណឌី!!

(ស្វាមី)៖ វណ្ណឌីហើយស្រីពៅហា!!

ក៖ ស្រីពៅ។

(ស្វាមី)៖ ថារី!!

ក៖ ថាវី!!គ្រប់៩នៅពូ?

(ស្វាមី)៖ នៅទេ។

ក៖នៅអ្នកណាគេទៀត?

(កូន)៖ នៅស្រីទូច អាពុធ។

(ស្វាមី)៖ ស្រីទូច ថាវិន។

ក៖ ថាវិន!!

(ស្វាមី)៖ នេះកូន៧ ព្រំ ពុធ !!រកឈ្មោះមិនទាន់ដាក់ទៅវាកើតថ្ងៃពុធដាក់ឈ្មោះពុធម៉ងទៅ។

ក៖ ដាក់ព្រំពុធអីចឹងទៅ!!

(ស្វាមី)៖ ប៉ុន្តែក្បាលខូចណាស់នេះ!!

ក៖ ហ៊ីមាឌបានដែរតើហិ!!

(ស្វាមី)៖ ចុះបើបាយ២ខ្លាំ!

ក៖ រកស៊ីអត់ទាន់!! ចាំ
អញ្ចឹងមីងកូនអ្នកមីងទាំង៩នាក់ហ្នឹងទាំង១០តែគាត់ស្លាប់មួយហើយមីងមានអោយពួកគាត់ទៅរៀនអីអត់?

ខ៖ រៀន!!

(ស្វាមី)៖ អោយរៀនគ្រប់ក្បាលទាំងអស់ហ្នឹង!!

ក៖ តែទាំងអស់គ្នាមានអ្នកណាគេនៅរៀនទល់សព្វថ្ងៃ។

(ស្វាមី)៖ អានេះថ្ងៃចូលឆ្នាំហើយអោយចូលវិញ ២នាក់បងប្អូនហ្នឹង!!!!

ក៖ ហើយបានទៅរៀនខ្លះៗ?

(ស្វាមី)៖ នៅ នេះអញ្ចេកអានេះបានរៀន៩ឆ្នាំហើយនៅតែទី១។

ក៖ អ៊ីចឹង៨ឆ្នាំហើយនៅរៀនតែទី១កូនមួយហ្នឹង?

ខ៖ ទី១ទី១ហ្នឹង។

ក៖ ចា៎អ៊ីចឹងក្រៅពីហ្នឹងនៅតែមួយហ្នឹងរៀនទេហី?

ខ៖ ២នាក់។

ក៖ ២នាក់ហោ?

ខ៖ ២នាក់ទៀតគឺទៅតាមម៉ែហ្នូ!!ទៅតាមម៉ែបាត់ហើយ(តាមម្ដាយរបស់អ្នកមីង)។

ក៖ ចា៎!!ហោមីង ដល់មានបងប្អូនតែ២នាក់អ៊ីចឹងបានយកកូនច្រើន
អោយបានច្រើនអ៊ីចឹងទៅកូនឡើងលញ៉ុងកុំអោយដូចមីង ទោះម៉េចបើស្លាប់មួយក៏នៅមួយដែរ
បងប្អូនតែ២នាក់តែកូន១០ហ្នឹងហើយ
អ៊ីចឹងមីងមូលហេតុអីដែលអ្នកមីងចង់អោយកូនទៅរៀនដែរ?

(ស្វាមី)៖ ចង់អោយកូនចេះ។

ខ៖ ចង់អោយកូនចេះ ដល់តែវាមិនទៅរៀនមិនដឹងធ្វើម៉េចទេ
បើវាលែងទៅរៀនលែងទៅអីអស់ហើយ ហើយណាមួយអត់មានលុយអោយវាទៅរៀនទៀត
គ្រូយកលុយទៅទៀតពិបាកទៀតហា៎!!

(ស្វាមី)៖ ហ៊ីឥឡូវគ្រូលែងយកលុយហើយ តែវាមិនទៅ។

ខ៖ តែវាមិនទៅ។

ក៖ ចា៎ហ្នឹងហើយ ឥឡូវអ្នកមីងនិយាយពីជីវិតអ្នកមីងនៅក្នុងសម័យសង្គ្រាម
ដោយសារអ្នកមីងកើតទាន់ទាំងជំនាន់ប៉ុល ពត នឹងជំនាន់លន់ នល់ អាពេលលន់ នល់
វាមុនជំនាន់ប៉ុល ពតមែនមីង ។

ខ៖ ចា៎!!

ក៖ តែពេលអាពតជំនាន់ លន់ នល់ ហ្នឹងមិនគេចគ្រាប់គេចអីមែនទេ លឺចាស់ៗនិយាយញ៉ុម។

ខ៖ ញ៉ុមក៏គេចគ្រាប់ដែរ គ្រង់ សេ។

ក៖ ហ្នឹងហើយ ឥលូវមីងនិយាយមើល មីងគេចគ្រាប់ម៉េចដែរ?

ខ៖ គេចគ្រាប់ខ្លាចត្រូវគ្រាប់ងាប់ហ្នឹង។

ក៖ តែគេចគឺដឹងថាខ្លាចត្រូវគ្រាប់ងាប់ហើយ មីងនៅណាវិញ ពេលជំនាន់លន់ នល់
នៅកំពង់កោរដដែល?

ខ៖ នៅដដែលហ្នឹង។

ក៖ ចាំ!!

ខ៖ ហ្នឹងហើយ។

ក៖ ពេលហ្នឹងផ្លោងគ្រាប់ទៅដល់ហ្នឹងទេមីង?

ខ៖ ឡើងទៅដល់ហ្នឹង ហួសហ្នឹងទៅ ចេះតែក្រាបទៅ។ក៖ចាំ!!ខ៖ ហ្នឹងហើយចេះតែក្រាបទៅ។

ក៖ ហើយវាម៉េចខ្លះទៅ លឺម៉េចខ្លះទៅបានដឹងថាគ្រាប់ទំលាក់មក?

ខ៖ លឺសូរដុង នាំកូននាំនេះ !! កាលហ្នឹងមិនទាន់បាននេះទេ មិនទាន់បានឪវានៅ
ខ្ញុំមិនសូវចាំដែរហ្នឹងហាំ !!

ក៖ចាំ!!

ខ៖ ខ្ញុំមិនសូវចាំ។

ក៖ តែគ្រាន់តែដឹងថាមានទំលាក់គ្រាប់ហើយមានជីកត្រង់សេដែរហ្នឹងហេ??

ខ៖ ចាំ!!

ក៖ ហើយអ្នកណាគេ ឪពុកម្តាយជាអ្នកជីកអារូងហ្នឹងឬក៏មីងអីវ៉ាន់ជួយជីកដែរ?

(ស្វាមី)៖ ចូលរួមជាមួយ។

ខ៖ ចូលរួមជាមួយគ្នាហ្នឹង។

កះ ជីកជ្រៅទេមីង?

ខះ ជីកហ្នឹងដំបូលយើងធ្វើដូចផ្ទះអ៊ីចឹង រុនប៉ុណ្ណឹងទៅ នាំគ្នាចូលទៅ
ចូលទៅមួយក្រុមគ្រួសារហ្នឹងចូលត្រង់សេតែមួយហ្នឹង ។

កះចាំ!!

ខះ ចាំ!!

កះ ហើយដកដង្ហើមរួចទេ?

ខះ ហ៊ីនេះមានខ្យល់វាដែរតើ!!

កះហ្ហ៎!!

ខះ គេធ្វើខ្យល់វាដែរហ្នឹង។

កះហ្ហ៎!!

ខះហ្នឹងហើយធ្វើដំបូងធ្វើអីដូចយើងប្រកផ្ទះអ៊ីចឹង។

កះ អាហ្នឹងជីករណ្តៅមែនមីង?

ខះ ហ្នឹងហើយជីករណ្តៅ ។

(ស្វាមី)៖ វាទៅអញ្ចេក។

កះ ជីករណ្តៅវែងអញ្ចឹងទៅ?

ខះ ចាំ!!

កះយកអីមកក្រុបអ៊ីចឹងទៅ?

(ស្វាមី)៖ យកអាដេញមែកឈើមែកអី។

ខះ មែកឈើ។

(ស្វាមី)៖ មករៀបអ៊ីចឹងទៅដាក់រៀបទៅ។

ខ៖ រៀបទៅយកដីមកដាក់ក្របពីលើ។

ក៖ចាំ!!

ខ៖ ហ្នឹងហើយយកដីមកដាក់គ្របពីលើ បើថាអត់សង្គ្រាមអ៊ីចឹងនាំគ្នាមកចេញក្រៅអ៊ីចឹង ហ្នំមើលតែសង្គ្រាមមកហើយនាំគ្នារត់ចូលត្រង់សេហើយ។

ក៖ចាំ!!

ខ៖ ហ្នឹងហើយ។

ក៖តែបើសិនជាទំលាក់គ្រាប់ចំហ្នឹងក៏នេះដែរមើងហេ??

(ស្វាមី)៖ អត់អីទេ។

ខ៖ អត់អីដែរ។

ក៖ ទំលាក់គ្រាប់!!ចំត្រង់សេការពារបានសាហាវណាស់ហេ ទំលាក់គ្រាប់ចំហើយ។

(ស្វាមី)៖ ចុះបើគល់អំពិលទឹកប៉ុនៗនេះ។

ក៖ ហ្ន៎!!

ខ៖ ហើយអុជទៀន កាលហ្នឹងមានទៀនដែរតើ!!

ក៖ហ្ន៎!!!

ខ៖ កាលហ្នឹងមានទៀនដាក់ក្នុងនេះហ្ន៎ក្នុងដីហ្នឹងភ្លឺទៅ ភ្លឺទៅ!!

ក៖ចាំ!!

ខ៖ ហើយពេលភ្លឺអ៊ីចឹងនាំកូ
ននាំអីហូបបាយហើយអីហើយអ៊ីចឹងទៅនាំគ្នាចូលត្រង់សេអ៊ីចឹងទៅ។

ក៖ចាំ!!

ខ៖ ហ្នឹងហើយ។

ក៖ ហ្នឹងហើយ អ៊ីចឹងក៏បានរួចជីវិតអ៊ីចឹងទៅ?

ខ៖ ចាំ!!!

ក៖ អ៊ីចឹងចូលដល់ពេលជំនាន់ប៉ុល ពតវិញម្ដង តែបែកពេលជំនាន់ប៉ុល ពតចប់ចូលប៉ុល ពតហើយមីងណោះ?

ខ៖ ហ្នឹងហើយ។

ក៖ ជីវិតមីងម៉េចដែរនៅក្នុងជំនាន់ប៉ុល ពត?

ខ៖ តែម៉ោង៣ឡើង ថ្មើរហ្នឹងអត់ទាន់នេះទេអត់ទាន់ចូលផ្ទះទេ អត់ទាន់នេះទេណាស់ អត់ទាន់ចូលអង្គការ គេហៅអង្គការអង្គការហ្នឹង គេហៅសាម៉ាក់មិត្ត សាម៉ាក់មិត្តទេ ហ្នឹងហើយសាម៉ាក់មិត្តទេ!!សាម៉ាក់មិត្តទេអត់ហ៊ានហៅចំឈ្មោះទេ ហៅតែសាម៉ាក់មិត្តទេ ហើយថ្មើរហ្នឹងទៅរែកអាចមន៍គោរែកជីរែកអីទៅយកទៅស្រោចបន្លែអង្គការគេដាំជំនាំហ្នុំ!!រែកហ្នុំ កើបអាចមន៍គោយកមកស្រោចអ៊ីចឹងទៅ បើអ្នកថ្ងូរតែមួយម៉ាត់គឺបាត់ខ្លួនហើយ គឺបាត់ខ្លួនអ៊ីចឹងម៉ង ហើយដល់ពេលហូបបាយអោយតែដល់ម៉ោង៨យប់ ៨យប់យើងហ្នឹងហាំ!!ដឹងតែគេហៅយើងទៅហូបបបរ ហូបបបរ ហូបបបរហើយហើយ កូនកូនចានចង្កឹះយើងហ្នឹងហាំ!!ដឹងតែមួយកូនចានចង្កឹះហ្នឹងម៉ងអត់មានថែមអត់មានថយទេ តែប៉ុណ្ណឹងហ្នឹងម៉ងហើយដាក់អំបិលលមៗទេអំបិល អត់អោយនេះទេ បើសិនជានេះថាហ៊ី បបរហ្នឹងស៊ីអត់កើតទេ!!ដល់យើងសរសើរបបរហ្នឹងឆ្ងាញ់អាហ្នឹងវាអរ។

ក៖ឆ្កួត!!

ខ៖ បើថាស៊ីអត់កើតទេហ៊ីមិត្តឯងមើលងាយអង្គការ ។

ក៖ហ៊ឺៗ!!

ខ៖ អ៊ែយើងភ្លូមកំពុងស៊ីតែឥឡូវហ្នឹងអត់ហ៊ានអត់ហ៊ានមាត់ទេ ចេះតែនិយាយថាហ៊ីបបរឆ្ងាញ់ណាស់បបរយើងឆ្ងាញ់ណាស់

ហ៊ីអង្គការហ្នឹងគេអរគេហើយណាស់
សរសើរថាឆ្ងាញ់ហ្នឹងណាស់!ព្រោះអ្នកតាមដានយើងហ្នឹងអ្នកបបរ។

ក៖ហ្ហ!!

ខ៖ អ្នកតាមដានយើងហ្នឹងអ្នកបបរ អ៊ីចឹងទៅហ៊ីឆ្ងាញ់ណាស់ ចេះតែហូបទៅ តាមការពិតហ្នឹង
បបរវាអត់ឆ្ងាញ់ទេតែយើងចេះតែសរសើរទៅ

។

ក៖ បើមិនសរសើរវាយកទៅសម្លាប់?

ខ៖ ហ្នឹងហើយ។

ក៖ មីងមានធ្លាប់អ្នកណាគេរអ៊ូអីទេអត់មីង?

ខ៖ រឿងរអ៊ូវារអ៊ូហើយ តែវាអត់អោយលឺ!!

ក៖ អត់អោយលឺហេ?

ខ៖ ចាំអត់អោយលឺទេ!!

ក៖ចាំ!!!

ខ៖ ហ៊ីងហើយថូរថានឹកម៉ែហ្នឹងក៏អត់អោយនឹកដែរអត់អោយនឹកទេ
ហើយអ្នកខ្លះហូបអត់បានអ៊ីចឹងទៅហើមងាប់ក៏មានដែរ
ហើយដូចថាជីវភាពហ្នឹងអត់ដល់ហូបអត់ដល់ហាំ!!!!ហើមក៏មានដែរ!!

ក៖ហ៊ីៗ!!

ខ៖ ហ៊ីថា!

ក៖ វេទនាណាស់មីងណេះ?

ខ៖ វេទនាណាស់។

កៈ ហើយមីងនៅក្នុងកងកុមារហ្នឹង មីងនៅជាមួយពួកគាត់ហ្នឹងអីទាំងអស់ហ្នឹងហោ??

ខៈ ញ៉ុមនៅ នៅជាមួយម៉ែហ្នឹងហោ?

កៈ ហ្នឹងហើយ!បែកពីម៉ែហើយពេលហ្នឹងហោ?

ខៈ បែកពីម៉ែហ្នឹងអត់អោយនៅជាមួយទេ!!

កៈ អ៊ីចឹងនៅជាមួយកងកុមារគ្នាឯងហ្នឹងហោ?

ខៈ គ្នាឯងម៉ងនៅទូចៗម៉ង។

កៈ ចាំ!!ហើយពួកក្មេងៗបានអីវ៉ាន់ហូបអីគ្រប់គ្រាន់ទេ?

ខៈ ដូចគ្នា ។

កៈ ដូចគ្នាទាំងអស់ស្មើគ្នាទាំងអស់ហោ?

ខៈ ចាំដូចគ្នា។

កៈ ពេលមីងនៅប៉ុល ពតមីងនៅខេត្តណាវិញ?

ខៈ ទន្លេបាទីយើងហ្នឹងម៉ងហ្នឹង។

កៈ ហ្ហ៎ទន្លេបាទីហ្នឹងដដែលទេ?

ខៈចាំ!!

កៈ មីងអ្នកជំលៀសទៅឬក៏គេហៅអ្នកអីគេ!!អើរអ្នកថ្មីឬក៏អ្នកចាស់?អាពួក១៧នោះអីហ្ហ៎??

ខៈ អ្នកចាស់ហ្នឹង។

កៈ តែអ្នកចាស់គេថារស់នៅស្រួលជាងអ្នកថ្មីហី?

ខៈ ហ៊ីដូចគ្នាហ្នឹង ដូចគ្នាហ្នឹង។

(ស្វាមី)៖ កាលហ្នឹងពេលហ្នឹងវាមានបាយរួម។

ខ៖ បាយរួមបានតែម្តងទេ បើថាអង្គការ អង្គការដូចថាអង្គការគេធំៗហ្នឹងមកអីចឹងហាំ ដូចថាធ្វើបុណ្យ៧មករាអីចឹង(ឧទាហរណ៍ដូចជាបុណ្យ៧មករា)ណាស់ អាហ្នឹងបានបាយហូបមួយពេលដែរហាមួយថ្ងៃដែរ  ធ្វើអញ្ចឹងមួយថ្ងៃហ្នំ!!

ក៖ហ៊ឺ!!

ខ៖ អាអីចឹងបានបាយឆ្ងាញ់មួយថ្ងៃអីចឹងទៅ សំលការីឆ្ងាញ់អីចឹងទៅ បានឆ្ងាញ់មួយថ្ងៃអីចឹងទៅ។

ក៖ អីចឹងបានតែមួយឆ្អែតតែមួយថ្ងៃហ្នឹងទេ?

ខ៖ ចាំ!!

ក៖ អីចឹងមីងក្មេងៗដែលនៅជាមួយមីងនៅពេលដែលគាត់ហូបអត់បានគ្រប់គ្រាន់ មិញមីងនិយាយថាហើមស្លាប់មីងណេះ?

ខ៖ ហ្នឹងហើយ។

ក៖ ចុះមានដែលអ្នកណាគេដេកស្លាប់ទេមួយៗដឹងទេ?

(ស្វាមី)៖ មាន។

ខ៖ មាន។

ក៖ ចាំហើយដល់ពេលដឹងម៉េចទៅមួយៗអីចឹង?

ខ៖ ងាប់ទៅ!!

(ស្វាមី)៖ មិនដឹងធ្វើម៉េច!!

ខ៖ ងាប់ទៅ!!

ក៖ គេយកទៅកប់ឬក៏គេយកទៅក្រវត្តចោល?

ខ៖ បោះចោល បោះចោល បោះចោលទៅ មានយកទៅកប់ឯណា បោះចោលឆ្កែហែកស៊ី!!

(ស្វាមី)៖ មានរណ្តៅមួយសំរាប់បោះចូលទៅ!!

ខ៖ រណ្តៅ!! ហើយមានគេជីករណ្តៅហាំ !!គេជីករណ្តៅមួយដូចឆ្ងាយអីចឹងហិ
ដូចសហាករណ៍យើងអីចឹងទៅ គេជីករណ្តៅទុកហើយណាស់ ដូចថាសាគួរ
ដូចថាយើងធ្វើខុសអីចឹងគេអូសទៅពេលយប់ហើយអត់អោយម៉ែឪដឹងទេ
អត់អោយអ្នកណាដឹងទេដូចថាញ៉ុមធ្វើខុសអញ្ចឹងហាំ
គេគម់យើងអត់អោយយើងនិយាយអត់អោយយើងលឺអីទេណាស់
នេះសាម៉ាក់មិត្តិនេះមកណេះ!!ថាអញ្ចឹងហាំ សាម៉ាក់មិត្តនេះមកណេះ!
ហ៊ីហៅញ៉ុមធ្វើអី?ហ៊ីមក មក មក មិនបាច់សួរទេ!! ដោះខោអាវដោះអាវចេះ
មួយត្បូងចបហ្នឹងភ្ជួស កាយ កាយដីហ្នឹងលុបម៉ង អត់អោយយើងដកដង្ហើមទាន់ទេ
ហើយលឺសួរថាបាត់បុគ្គលណាមួយហិអត់អោយយើងសួររកទេ
ដឹងតែខ្លួនថាបាត់ហើយអត់អោយយើងសួររកទេ។

ក៖ គេប្រកាសប្រាប់ថាអញ្ចឹងម៉ងឬក៏ម៉េចមីង?

ខ៖ អត់ទេ អត់អោយសួរទេ ដឹងថាខ្លួនបាត់អត់អោយសួររកទេ។

ក៖ ដឹងថាពួកម៉ាក់ឬក៏អ្នកនៅជាមួយបាត់ហ្នឹងហេ?

ខ៖ ហ្នឹងហើយ ពួកម៉ាក់ហើយនឹងក្មេងៗអីចឹងទៅណាស់ ហើយម៉ែឪអញ្ចឹងទៅណាស់
ម៉ែឪអីវ៉ាន់ថាម៉ែឪយើងហ្នឹងអីវ៉ាន់បាត់អីចឹងៗទៅ អត់អោយសួររកឪពុកម្តាយទេ
អត់អោយសួររកទេដឹងថាឪពុកម្តាយរបស់យើងគេយកទៅវ៉ៃចោលទៅណាស់
អត់អោយយំអត់អោយអីទាំងអស់។

ក៖ តែឃើញ ?

ខ៖ ឃើញដោយមិនដឹងធ្វើម៉េច យើងឃើញឧបមាថាម៉ែយើងអញ្ចឹង
ម៉ែយើងខុសអីក៏វាមអត់មានប្រាប់ថាម៉ែយើងធ្វើនេះខុសអត់ប្រាប់ទេ
ដឹងតែយកទៅវ៉ៃចោលម៉ងឃើញតែខោអាវទេ ។

ក៖ សាហាវណាស់មីងណោះ?

ខ៖ តែមុនគេយកយើងទៅវ៉ៃចោលហ្នឹងហាំ!! គេអោយយើងហូបមួយឆ្អែត
មួយឆ្អែតបរបូរម៉ងបានគេយកយើងទៅវ៉ៃចោលក្រោយ ។

ក៖ គេចិត្តល្អអញ្ចឹងទៀត?

ខ៖ ហ្នឹងហើយ។

ក៖ អាហ្នឹងមិនដឹងមានន័យថាយ៉ាងម៉េចទេ!!

ខ៖ ហ្នឹងហើយ។

ក៖ អោយដូចរបៀបវាថាអោយឆ្អែតមុននឹងស្លាប់អញ្ចឹង!!

ខ៖ ហ្នឹងហើយ។

ក៖ កុំអោយស្លាប់ទៅអត់ឃ្លានអីចឹងហេ?

ខ៖ ចាំ!!

(ស្វាមី)៖ អាហ្នឹងគេអោយស៊ីផ្តាំហាំ!!

ខ៖ ហ្នឹងហើយ។

ក៖ ហើយមីងដល់ពេលជំនាន់ប៉ុល ពត
ដល់ពេលហូបអត់គ្រប់គ្រាន់អីចឹងមីងមានដែលទៅរករបស់គេឬក៏លួចអីហូបអីអត់?

ខ៖ ហ៊ុ ដល់ពេលអត់អីហូបអីចឹងណាស់ ជួនកាលដើរបេះស្លឹកឈើហូបក៏មានដែរ
ចុះវាហូបអត់ឆ្អែតអញ្ចឹងដើរបេះស្លឹកឈើហូបតើ!!អាស្វាយ
ក្តិបស្វាយអាគេដាក់ដាំហ្នឹងហាំអង្គការគេដាក់ដាំហ្នឹងហាំក្តិបៗហ្នឹងលួចបេះហូបហ្នឹងទៅ
អាអំបិលគ្រោះយើងអាយើងយកពីកន្លែងចុងភៅហ្នឹងមកហ្នឹងហាំ!!លូនទៅលូនទៅហ្នឹងបេះ
ហើយ លូនហើយភ្នែកសរស្តោះ គេមក គេមកបោះចោលហើយ លើកបង្គី
លើកអាចមន៍គោទៅទៀតហើយ!! អីគេនៅក្នុងហោរប៉ៅទូងៗ??អត់មានអីផង
ឆែកទៅឃើញក្តិបអំពិល ក្តិបស្វាយហ្នឹងហ្នឹង នាងឯងយប់ហ្នឹងបាត់ហើយ បាត់ខ្លួនហើយ។

ក៖ ចុះពេលបេះបានហ្នឹងមិនព្រមហូបអោយហើយម៉ងទៅអត់ទេ។

ខ៖ ថាអាកំពុងស៊ីហើយហ្នឹង កំពុងដាក់នៅហ្នឹងមាត់ហើយហ្នឹងមកដល់ពិប។

ក៖ ដូចទាហានហ្នឹងនៅពេញហ្នឹងម៉ងមីងហេ ពួកអាឆ្លបហ្នឹងស្អីគេហ្នឹង?

ខ៖ នៅពេញហ្នឹង វាការពារនៅហ្នឹង ២៤ម៉ោងនៅហ្នឹងអ៊ិចឹង ។

ក៖ វាប៉ុនម៉ង!! ហើយអ៊ិចឹងអើរដូចរបៀបអ្នកដែលធ្វើឆ្លបហ្នឹងអ្នកមកពីណាវិញមីងដឹងទេ?

ខ៖ ហាំ?

ក៖ អ្នកមីងពីណាអ្នកនៅក្នុងស្រុកភូមិហ្នឹង?

ខ៖ នៅក្នុងភូមិហ្នឹងម៉ងហាំ!!

ក៖ ធ្លាប់ស្គាល់គ្នាពីមុនមកទេ?

ខ៖ ស្គាល់គ្នាពីមុនមកនៅហ្នឹង នៅហ្នឹង។

ក៖ តែពីមុនធ្វើអញ្ចឹងគាត់អត់មានអីណាហី គាត់អត់មានខូចអាក្រក់អីណាហី?

ខ៖ ដោយមនុស្ស ឆ្លបអីវ៉ាន់ មេកង គេហៅមេកង ហើយនឹងហ្នឹង
គេហៅសាម៉ាក់មិត្ត។ក៖ចាំ!!ខ៖ សាម៉ាក់មិត្ត សាម៉ាក់មិត្តទេ។

ក៖ ហ្នឹងហើយ។

ខ៖ ដល់អ្នកនេះអ៊ីចឹងទៅហៅអ៊ីចឹងទេ ណៃសាម៉ាក់មិត្តអត់ហៅចំឈ្មោះអ្នកនេះទេអ្នកនេះទេ
ហៅតែសាម៉ាក់ទេ។

ក៖ចាំ!!

ខ៖អង្គការគេ។

ក៖ អត់អោយហៅឈ្មោះអីឈ្មោះអីទេ តែហៅហ្នឹងខុសទៀត!!

ខ៖ ហ្នឹងហើយ។

(ស្វាមី)៖ កន្លែងខ្លះគេហៅដែរ។

ខ៖ អត់ទេកន្លែងញុំមអត់មានហៅឈ្មោះទេ ហៅតែសាម៉ាក់មិត្តទេ។

ក៖ ហ្ន៎អញ្ចឹងកន្លែងមីងផ្សេងកន្លែងពូផ្សេងអ៊ីចឹង!!

ខ៖ ហ្នឹងហើយ។

ក៖ អ៊ីចឹងមីងមីងឯងធ្លាប់ឃើញគេវ៉ៃមនុស្សអីអត់ យកមនុស្សទៅសម្លាប់ចោលអីនៅមុនអីអត់?

ខ៖ អត់ដែលឃើញទេ។

ក៖ អត់ដែលឃើញដែរហេ?

ខ៖ អត់អោយឃើញម៉ង អោយតែខឹងហើយ !!វ៉ៃពេលថ្ងៃអត់អោយទេ
វ៉ៃពេលយប់កណ្ដាលអាធ្រាតយើងកំពុងតែដេកហ្នឹងហៅហើយ ហៅខ្សឹបៗទៅហើយ
ណែសាម៉ាក់មិត្តឯង !!ណែពូហៅញុំមទៅណា? ហេមិនបាច់សួរទេ មេគេធំឈរចាំបញ្ជាម៉ង
អាកំពុងដោះអាវដោះខោអស់រលីង មួយត្បូងចបអាចបកាប់យើងហ្នឹងហាំដាក់ម៉ងភ្លូស
ប្រានចូលទៅក្នុងរណ្ដៅម៉ង កាយដីលុបម៉ងអត់អោយដកដង្ហើមទាន់ទេ។

ក៖ ហ៊ុសាហាវណាស់មីងអើយ!!

ខ៖ ហ្នឹងហើយ។

ក៖ តែគ្រាន់តែមីងដឹងអ៊ីចឹង !!
ហើយមីងដែលឃើញមនុស្សគេចងទាំងខ្សែទាំងខ្សែយកទៅអីអត់?
ខ៖ ឃើញស្រាតអស់រលីង មួយជួរ។

ក៖ ទាំងថ្ងៃហ្នឹង?

ខ៖ ហ្នឹងហើយ។

(ស្វាមី)៖ អត់ទេអាទាំងខ្សែហ្នឹងច្រើនតែពេលយប់។

ខ៖ ពេលយប់ ពេលយប់ ញុំមលួចមើល ចេះតែញុំមលួចមើលឃើញ តាមលួចមើលហ្នឹង
មើលហើយមើលទៀត មើលហើយធ្វើដេកហើយ អាឯងនេះញាក់សាច់អញ្ចេក ញាក់អញ្ចេក!!
ឃើញគេវ៉ៃទាំងស្រស់ៗពេកហ្ន៎!! ញាក់សាច់ម៉ង ញាក់សាច់ម៉ង។

កៈ ទាំងជីវិតគេជីវិតយើងមីងណោះ?

ខៈ ហ្នឹងហើយ ។

កៈ ចេះតែអានោចអាធមហើយ។

ខៈ ចាស់ផ្សេងក្មេងផ្សេង អត់មានអោយឪពុកម្ដាយហ្នឹងហា អត់មានអោយឪពុកម្ដាយឪ ដូចថាអត់អោយដេកនៅជាមួយគ្នាទេ ដូចថាម្ដាយដាក់ដោយខ្លួនឪនៅដោយខ្លួន។

កៈ អញ្ចឹងប្រុសៗនៅប្រុសៗស្រីៗនៅស្រីៗ?

ខៈ ចា៎!!!

កៈ កុមារនៅកុមារ ចាស់ៗនៅចាស់ៗទៅ?

ខៈ ចា៎!!

កៈ ហើយចាស់ៗខ្លះហា៎ អត់មានជីវជាតិ ដូចថាអត់មានជាតិប្រៃ អត់មានជាតិប្រៃអីចឹងទៅណាស់ទៅជាហើមចេញទឹកក៏មានដែរ។

កៈហ៊ឺៗ!!

ខៈ ហើមចេញទឹកក៏មានដែរ ចុះវាហូបអត់ជិតដល់ ជំនាន់អាពតហូបអត់ជិតដល់ទេ!!អាហ្នឹងអីចឹង។

កៈ ចុះមីងសំរាប់ម្ដាយឪពុកមីងមានបានឮអីគេខ្លះពីម្ដាយឪពុកទេរបស់មីង?

ខៈ អត់មានបានឮអីទេ ។

កៈ តែគាត់អត់មានអីដែរណាអ្នកមីងហី?

ខៈ ម៉ែញ៉ុមអត់តអីទេ ។

កៈ គាត់មានដែលប្រាប់មីងពីថាគាត់រងទុក្ខអីគេខ្លះអីអត់នៅក្នុងពេលហ្នឹង?

ខ៖ ដល់ម៉ែញ៉ុមគាត់អត់រងទុក្ខ គាត់តអត់មានរងទុក្ខអីទេ ម៉ែញ៉ុមអត់អីដែរ ម៉ែញ៉ុមអត់អីទេ!!បើខាងគាត់អត់ដឹងម៉េចទេណាស់ ព្រោះគាត់អោយបែកគ្នារហូតហ្នឹង។

ក៖ តែដឹងថាគាត់អត់អី?

ខ៖ ដឹងតែគាត់អត់អីទេ។

ក៖ ហេងហើយដែលគាត់មានជីវិតមករស់នៅដល់សព្វថ្ងៃមីងណោះ?

ខ៖ ហ្នឹងហើយ ។

ក៖ ចាំ!!មីងដល់ពេលបែកពីជំនាន់ប៉ុល ពតមកមីងរស់នៅជាមួយម្ដាយមកហេ?

ខ៖ ចាំ!!

ក៖ មីងចាំថ្ងៃចុងក្រោយនៃជំនាន់ប៉ុល ពតនៅពេលដែលវៀតណាមចូលមកស្រុកខ្មែរមីងចាំពេលហ្នឹងទេ?

ខ៖ អត់បានចាំផង។

ក៖ អ៊ីចឹងពេលថ្ងៃចុងក្រោយមីងម៉េចដែរ?

ខ៖ ថ្ងៃចុងក្រោយដឹងថាគេរំដោះ គេរំដោះអើរ ពួកអាពួកវៀតណាមហ្នឹង វាមករំដោះពួកខ្មែរយើងហ្នឹងពីជំនាន់ប៉ុល ពតហ្នឹងហាំបានជួបជុំគ្នានឹងម្ដាយហ្នឹងគ្នាអរណាស់!! គ្នាអោប ម៉ែថើបកូនកូនថើបម៉ែអញ្ចឹងទៅបានសុខសាន្តអ៊ីចឹងទៅទាល់តែសព្វថ្ងៃអ៊ីចឹងទៅ។

ក៖ចាំ!!

ខ៖ហ្នឹងហើយ។

ក៖ ពេលហ្នឹងបានអីហូបស្រួលប្រួលអីវិញហើយមីងណោះ?

ខ៖ ហ្នឹងហើយ។

ក៖ អ៊ីចឹងគ្រាន់បើហើយបានរួចផុតមួយៗ!!

ខ៖ ហ្នឹងហើយ រួចផុតរួចទោសអីអស់ហើយ។

ក៖ ចាំហ្នឹងហើយ។

ខ៖ ហ្នឹងហើយទល់តែសព្វថ្ងៃហ្នឹងទៅ។

ក៖ ចាំ!!អញ្ចឹងមីងបន្ទាប់ពីពេលបែកជំនាន់ ប៉ុល ពតមីងហើយនឹងម៉ែអីវ៉ាន់ធ្វើស្រែអីទៀតទៅ?

ខ៖ ធ្វើស្រែធ្វើអីហ្នឹងអីចឹងទៅ
ធ្វើស្រែធ្វើអីអញ្ចឹងបានចាប់ផ្ដើមប្រកបមុខរបរលក់ដូរអញ្ចឹងទៅណាស់!!

ក៖ចាំ!!

ខ៖ ប្រកបមុខរបរលក់ដូរតិចតួច ចិញ្ចឹមជីវភាពអញ្ចឹងទៅដល់សព្វថ្ងៃហ្នឹងអញ្ចឹងទៅ
ហ្នឹងហើយ។

ក៖ អញ្ចឹងអ្នកមីងសំរាប់ជីវិតរបស់អ្នកមីង អ្នកមីងធ្លាប់ធ្វើរបរធ្វើស្រែចំការ ខ្សែ
អីហាលខ្សែលក់ អីគេទៀត?

ខ៖ វិញខ្សែលក់ហ្នឹង ហើយលក់បាយ។

ក៖ លក់បាយដែរ?

ខ៖ លក់បាយ
លក់បាយទៅមើលទៅជំពាក់គេច្រើនពេកអីចឹងទៅនឹងហាំបានដើរលក់នេះលក់បន្លែ
មុខដំបូងមានតែ១៥០០គត់ ដើរទិញព្រលិតលក់ ទិញព្រលិតលក់អញ្ចឹងទៅ
ដើរបេះស្លឹកបាសអញ្ចឹងទៅ អញ្ចឹងទៅហា
បេះស្លឹកបាសចងជ្រលក់ទឹកជ្រលក់អីអញ្ចឹងចេះតែលក់ទៅ
រាប់លុយគេចងការគេអញ្ចឹងទិញបន្លែលក់ ទិញបន្លែលក់អីចឹងទៅ
ប្រកបមុខរបរអញ្ចឹងទៅទិញបានចានដែកហ្នឹងតិចទៅ លក់គ្រប់តែមុខ អាស្ពៃហ្នឹងបន្តិចទៅ
ស្ពៃក្រញាញ់ហ្នឹងខ្លះទៅ កាឆយហ្នឹងខ្លះទៅហ្នឹងហាំ!! លក់ទៅបានបន្តបន្ទាប់
បានចិញ្ចឹមកូនចិញ្ចឹមចៅអញ្ចឹងទៅដល់ពេល ដល់ពេលឥឡូវហ្នឹងប៉ូលីសដេញពេក
ដល់ប៉ូលីសដេញពេកចាប់ចានដែកចាប់អីអស់ទៅញ៉ុមផ្អាកលក់ បានញ៉ុមផ្អាកលក់ហ្នឹង។

កៈចាំ!!

ខៈ ផ្អាកលក់ហ្នឹងបានញ៉ុមដើររើសអេតចាយអីហ្នឹងដើររើសអេតចាយអីទៅ។

កៈ អញ្ចឹងគ្រាន់បានចិញ្ចឹមកូនចិញ្ចឹមចៅអីវ៉ាន់ទៅមីងណោះ?

ខៈ ចាំ!!

កៈ ចាំ!!អ៊ីចឹងមីងសំរាប់ចំនង់ចំនូលចិត្តរបស់មីងមីងចូលចិត្តពិសារហូបអីគេជាងគេ?

ខៈ  អត់មានអីទេ ជូនណាលហ្នឹង និយាយអោយចំ ជូនណាលហ្នឹងកូនដើរសុំទានគេហ្នឹង ដើរសុំទានគេទៅ បានសាច់ជ្រូកហ្នឹងខ្លះទៅ ត្រីហ្នឹងខ្លះទៅប្រលាក់ទៅ គ្រាន់ហូបទៅទៅ ជូនណាលអត់ទៅ អាហ្នឹងវាអញ្ចឹង។

កៈ មីងមានស្អីសង្ឃឹមនៅក្នុងជីវិតដែរទៅថ្ងៃខាងមុខទៅ?

ខៈ អត់អីដែរហ្នឹង អត់មានសង្ឃឹមទេ។

កៈ ហើយកូនៗធំៗអស់ហើយចិញ្ចឹមម៉ែទៅ?

(ស្វាមី)៖ ចុះកូនៗពិតតែថាអញ្ចឹងមានប្ដីមានប្រពន្ធ!!

កៈ ចុះបើពេលមុនខំចិញ្ចឹមកូនចង់ងាប់ កូនមិនចិញ្ចឹមម៉ែម្ដង ម៉ែឪចិញ្ចឹមឡើង៩នាក់ចិញ្ចឹមម៉ែមួយឪមួយអត់រស់។ ហើយអញ្ចឹងមីង មីងមានអីគេពាក្យពេចន៍ចុងក្រោយចង់ផ្ដែផ្ដាំទៅកាន់កូនមីងក្រោយថាចង់អោយគាត់ដើរលើផ្លូវម៉េចដែរអ៊ីចឹងទៅណាស់?

ខៈ ចង់អោយកូនរៀនអោយដិតដល់ទៅ!!

(ស្វាមី)៖ ដើរតាមផ្លូវល្អ!!

ខៈ អោយកូនដើរតាមផ្លូវល្អ កុំអោយដើរតាមផ្លូវអាក្រក់អ៊ីចឹងទៅ។

កៈចាំ!!

ខៈ ហ្នឹងហើយ។

កៈ មីងមានអីចង់និយាយទៀតអត់?

ខៈ បានហើយអស់វាលែងមានពាក្យអីទៀតហើយ!!

កៈ ហ្នឹងហើយ
អ៊ីចឹងអ្នកមីងអរគុណច្រើនសំរាប់ការដែរអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងហើយអ្វីទាំងអស់កូនចៅរបស់មីងគាត់នឹងបានស្តាប់លឺពីជីវិតរបស់មីងណាស់មីង!!

ខៈ ចាំ!!

កៈ អ៊ីចឹងអរគុណច្រើនណាស់មីង។